ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០១១/២១ - ធៀន ស៊ុង ហ្គាមេន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១
យោបល់ជំទាស់ទៅនឹងសេចក្តីបង្គាប់ ៖ ដោយអាជ្ញាកណ្តាល ស៊ីន គីមស៊ាន

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ម៉ារ សំបូរណា**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គីមស៊ាន**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ធៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិព្រៃព្រីងខាងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៦ ៧០ ៦១ ៦៨ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

១- លោក តាំង ស៊ុនហេង ប្រធានរដ្ឋបាល
២- លោកស្រី សុខ រតនៈ ជំនួយការរដ្ឋបាល
៣- លោក យ៉ុំ ថៃសាន ទីប្រឹក្សាក្រុមហ៊ុន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **សហជីពប្រជាធិបតេយ្យកម្មករ នៃរោងចក្រ ធៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិព្រៃព្រីងខាងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៥ ៣០០ ៤៦៤ / ០១២ ៥០៤ ១៥៤ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖ ទូរសារ ៖ គ្មាន

១- លោក គង់ អាទិត្យ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ◆ Website: www.arbitrationcouncil.org

| | |
|---|---|
| ២- លោក ស៊ាង យ៉ូត | មន្ត្រីដោះស្រាយវិវាទសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៣- លោក សាអ៊ី រិទ្ធ | មន្ត្រីស្ម័គ្រចិត្ត សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៤-លោកស្រី មាស វណ្ណី | មន្ត្រីផ្នែកច្បាប់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៥- លោក សែម សុខណា | ប្រធានសហជីពប្រជាធិបតេយ្យកម្មករប្រចាំរោងចក្រ |
| ៦- លោក មាស សុជា | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករប្រចាំរោងចក្រ |
| ៧- លោក លន់ ដារ៉ា | លេខាសហជីពប្រជាធិបតេយ្យកម្មករប្រចាំរោងចក្រ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ថ្នាក់ដឹកនាំសហជីព និងកម្មករនិយោជិត ទាមទារឱ្យក្រុមហ៊ុនអនុវត្តខ្លឹមសារនៃអនុសញ្ញារួមទាំងមូល និងជាពិសេសត្រង់ប្រការ១៣(ខ) នៃអនុសញ្ញារួម ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តរួចហើយ ដែលបានកាត់ថ្លៃសេវាភ្នាក់ងារតែម្តងគត់ ដោយអនុវត្តតាមច្បាប់ស្តីពីសហជីព ដែលចាប់អនុវត្តពីខែកក្កដា ឆ្នាំ២០២០ ចំពោះកម្មករនិយោជិតដែលចូលធ្វើការងារថ្មី គឺក្រុមហ៊ុនអនុវត្តដូចគ្នាដែរ។

២- ថ្នាក់ដឹកនាំសហជីព និងកម្មករនិយោជិត ទាមទារឱ្យនិយោជកសងប្រាក់បង់តម្លៃសេវាភ្នាក់ងារអនុសញ្ញារួម ចាប់តាំងពីថ្ងៃអនុវត្តអនុសញ្ញារួមថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ រហូតដល់ការដោះស្រាយវិវាទនេះចប់សព្វគ្រប់ ការទាមទារនេះ ចំពោះតែចំនួនកម្មករនិយោជិតដែលមិនបានចូលជាសមាជិកសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តទៅតាមច្បាប់ស្តីពីសហជីព។

៣- ថ្នាក់ដឹកនាំសហជីព និងកម្មករនិយោជិត ទាមទារឱ្យនិយោជកបញ្ឈប់ការរើសអើងសហជីពដែលមានភាពជាតំណាងបំផុត។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនមានការរើសអើងសហជីពនោះទេ។

៤- ថ្នាក់ដឹកនាំសហជីព និងកម្មករនិយោជិតទាមទារឱ្យនិយោជកបញ្ឈប់ការបង្ខិតបង្ខំឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោង។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុននឹងព្យាយាមអនុវត្តទៅតាមគោលការណ៍ច្បាប់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និង ប្រកាសស្តីពីការតែងតាំង

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាម ជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី លេខ ៤២៤ ក.ប/អក/វក ចុះថ្ងៃពុធ ១៤កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ នាយកដ្ឋានវិវាទការងារ បានទទួលលិខិតជូនដំណឹងធ្វើកូដកម្មអហិង្សារបស់សហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូលិធីឌី ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ៤ចំណុច។ បន្ទាប់ពីបានទទួលបានលិខិតជូនដំណឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សានៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ចំណុចមិនសះជាចំនួន ៤ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូលិធីឌី លេខ ៤២៤ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១។ ដោយមូលហេតុនៃឆ្លងរាលដាលជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ និងដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាល ភាគីសហជីព(តំណាងកម្មករនិយោជិត) និងភាគីនិយោជកបានព្រមព្រៀងគ្នាស្នើសុំព្យួរនីតិវិធីសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រាប់សំណុំរឿងនេះ។ បន្ទាប់ពីបានទទួល និងពិនិត្យលើលិខិតស្នើសុំនេះ ក្រុមអាជ្ញាកណ្តាលទទួលបន្ទុកសំណុំរឿង បានឯកភាពលើការស្នើសុំព្យួរនីតិវិធីសវនាការរបស់ភាគីទាំងពីរ។ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ភាគីកម្មករនិយោជិតបានស្នើសុំបន្តនីតិវិធីសវនាការឡើងវិញ និងបន្ទាប់ពីទទួលបានការស្នើសុំនេះ។ ប៉ុន្តែ ដោយសារក្នុងកំឡុងខែកក្កដា ឆ្នាំ២០២១នេះ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលមានបុគ្គលិកមានវិជ្ជមានកូវីដ-១៩ ហើយដើម្បីគោរពតាមវិធានការសុខាភិបាល និងបង្ការការឆ្លងរាលដាលបន្តនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ហេតុនេះ ការិយាល័យក្រុមប្រឹក្សាអាជ្ញា-កណ្តាលត្រូវបានបិទ ដែលធ្វើឱ្យលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនអាចរៀបចំសវនាការបានឡើយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់យកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ២ និង ០០ នាទីរសៀល សម្រាប់ធ្វើសវនាការនៃសំណុំរឿងនេះ។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញ

THE ARBITRATION COUNCIL

ភាគីនិយោជក និងភាគីសហជីពមកសវនាការ និងផ្សះផ្សាលើករណីមិនសះជា នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ២ និង ០០ នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការតាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដើម្បីគោរពតាមវិធានការសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសដើម្បីរក្សាគម្លាតសុវត្ថិភាព ក្រុមអាជ្ញាកណ្តាលធ្វើសវនាការអនឡាញ ដោយប្រើប្រព័ន្ធហ្ស៊ូម (zoom) និងបន្ទប់សវនាការត្រូវបានបែងចែករវាងភាគីនៃវិវាទ និងក្រុមអាជ្ញាកណ្តាល។ នៅក្នុងសវនាការ ភាគីទាំងពីរមិនមានការជំទាស់ចំពោះនីតិវិធី និងមធ្យោបាយធ្វើសវនាការរបស់ក្រុមអាជ្ញាកណ្តាលនោះទេ។

ក្រុមអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៤ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយភាគីទាំងពីរបានព្រមព្រៀងគ្នាចំនួន ២ចំណុច គឺចំណុចវិវាទទី៣ និងទី៤ និងបានយល់ព្រមដាក់បញ្ចូលចំណុចវិវាទទី១ និងទី២ ជាចំណុចវិវាទតែមួយ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់ចំនួន ១ចំណុច គឺចំណុចវិវាទទី១ និងទី២។

នៅក្នុងសំណុំរឿងនេះ ភាគីបានជ្រើសរើសសេចក្តីបង្គាប់ជាប់កាតព្វកិច្ចយោងតាមអនុសញ្ញារួម។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ ឬភស្តុតាង និងថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ ឬភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតចុះថ្ងៃចន្ទ ៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ របស់អ្នកតំណាងភាគីនិយោជក នៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី និងអ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើរសុំព្យួរនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល សំណុំរឿងលេខ:០១១/២១ ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

២- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់លោក Chan Wing Kwong Richael ជានាយកក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូ អិលធីឌី ជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើរសុំផ្ទេរសិទ្ធិជូនលោក តាំង ស៊ុនហេង ជាប្រធានរដ្ឋបាល លោក យាំ ថៃសាន ជាទីប្រឹក្សា, លោក យ៉ូ បូរ៉ា ជាប្រធានផ្នែកអនុលោមច្បាប់, និងអ្នកស្រី រ៉ាត ស្រីផល ជាជំនួយការនាយកក្រុមហ៊ុន មានសិទ្ធិអំណាចពេញលេញក្នុងការដោះស្រាយរាល់បញ្ហា

វិវាទការងារក្នុងនាមតំណាងឱ្យម្ចាស់ ឬនាយកក្រុមហ៊ុន ព្រមទាំងមានសិទ្ធិសម្រេចរាល់កិច្ចព្រមព្រៀងផ្សេងៗផងដែរ ដើម្បីទំនាក់ទំនងជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល។

៣- វិញ្ញាបនបត្រលេខ MOC ៦៥៦៧៣៨៥៥ ពណ.ចបព ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូ អិលធីឌី។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ចុះទិដ្ឋាការ លេខ ១២៧ កប/អក/អធក ចុះថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ របស់នាយកដ្ឋានអធិការកិច្ចការងារ។

៥- លក្ខន្តិកៈក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូ អិលធីឌី បានតម្កល់ទុកលេខ ១៨៩០/០៨ ពណ.ចបព ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។

៦- អនុសញ្ញារួម រវាងសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជាមួយនិងក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី បានចុះបញ្ជីលេខ ០១៣កប/អក/វក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០។

៧- តារាងបញ្ជីបង់សេវាភ្ជាក់ងារ កម្មករនិយោជិត របស់ ក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

៨- កំណត់ហេតុប្រជុំ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកំណត់ថ្ងៃបើកប្រាក់ឈ្នួល និងថ្ងៃឈប់សម្រាកបុណ្យសម្រាប់ឆ្នាំ២០២១ ភ្ជាប់ជាមួយនឹងបញ្ជីវត្តមាន។

៩- កំណត់ហេតុប្រជុំ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ស្តីពី ប្រាក់បំណាច់អតីតភាពការងារ ភ្ជាប់ជាមួយនឹងបញ្ជីវត្តមាន។

១០- កំណត់ហេតុប្រជុំ ស្តីពីការកំណត់ថ្ងៃបើកប្រាក់បំណាច់ឆ្នាំ២០១៨ និងឆ្នាំ២០២០(០៧-១២)។

១១- លិខិតចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ របស់នាយកក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជូន ប្រធានសហជីពប្រជាធិបតេយ្យកម្មករ ស្តីពីករណីសហជីពស្នើសុំកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិត បង់ថ្លៃសេវាភ្នាក់ងារ នៃអនុសញ្ញារួម។

១២- លិខិតបដិសេធ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ របស់កម្មករ កម្មការិនីនៅរោងចក្រ ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ស្តីពី ស្នើសុំក្រុមហ៊ុនបញ្ឈប់ការកាត់លុយ ដើម្បីបង់ថ្លៃសេវាភ្នាក់ងារនៃអនុសញ្ញារួមសម្រាប់ធ្វើការងារថ្ងៃបុណ្យ ភ្ជាប់ជាមួយស្នាមមេដៃ។

១៣- បញ្ជីឈ្មោះ កម្មករនិយោជិតចុះខែឧសភា ឆ្នាំ២០២១ របស់ ក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី សម្រាប់កាត់លុយសហជីព ។

១៤- តារាងស្ម័គ្រចិត្តសុំបន្ថែមម៉ោង ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១, ០៩ ខែកក្កដា ឆ្នាំ២០២១, ០៨ ខែកក្កដា ឆ្នាំ២០២១, ០៧ ខែកក្កដា ឆ្នាំ២០២១, ០៦ ខែកក្កដា ឆ្នាំ២០២១, ០៩ ខែមិថុនា ឆ្នាំ ២០២១, ១០ ខែមិថុនា ឆ្នាំ២០២១, ១១ ខែមិថុនា ឆ្នាំ២០២១, ១៤ ខែមិថុនា ឆ្នាំ២០២១, ១៥ ខែមិថុនា ឆ្នាំ២០២១ របស់ ក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

១៥- បញ្ជីឈ្មោះអ្នកគ្រប់គ្រង គ្រប់ក្រុម គ្រប់ផ្នែក។

១៦- បញ្ជីឈ្មោះកម្មករនិយោជិត ចុះខែមិថុនា ឆ្នាំ២០២១ របស់ ក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី សម្រាប់កាត់លុយសហជីព ។

១៧- អនុសញ្ញារួម រវាងសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជាមួយនិង ក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតចុះថ្ងៃចន្ទ ៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ របស់ អ្នកតំណាងភាគីនិយោជកនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី និងអ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើរសុំព្យួរនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល សំណុំរឿងលេខ:០១១/២១ ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

២- លិខិតចុះថ្ងៃសុក្រ ៧កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ របស់ អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើរសុំបើកសវនាការតាមនីតិវិធីក្នុងសំណុំរឿងលេខ:០១១/២១ ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

៣- លិខិតលេខ ០៣៧/២១ ស.ប.ក/វិវាទ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីការចាត់តាំងលោក ស៊ាង យ៉ូត និង លោកស្រី មាស វណ្ណី ឱ្យជួយសម្របសម្រួលលើករណីវិវាទ តាមពាក្យបណ្តឹងរបស់កម្មករនិយោជិត ក្នុងសំណុំរឿង ០១១/២១ នៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

៤- កំណត់ហេតុ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ស្តីពីការបោះឆ្នោតធ្វើកូដកម្ម ដើម្បីដោះស្រាយបញ្ហាវិវាទមួយចំនួន ភ្ជាប់ជាមួយបញ្ជីឈ្មោះ និងស្នាមមេដៃកម្មករនិយោជិត។

៥- លិខិតចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ របស់កម្មករនិយោជិត ថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជូន នាយកក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ស្តីពីជូនដំណឹងស្តីពីការធ្វើកូដកម្មអហិង្សាតាមកំណត់នៃច្បាប់។

៦- វិញ្ញាបនបត្រលេខ១១៤ ក.ប/វ.ប.វ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពប្រជាធិបតេយ្យកម្មករនៃរោងចក្រ ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

៧- លិខិតលេខ ៤១៣ ក.ប/អក/វក ចុះថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ ជូន ប្រធានសហជីពប្រជាធិប-

THE ARBITRATION COUNCIL

តេយ្យកម្មករនៃរោងចក្រ ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ស្ដីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីព។

៨- វិញ្ញាបនបត្រលេខ ០១៧/២០ ក.ប/វ.ប.វ.ក ចុះថ្ងៃទី០៩ ខែ មករា ឆ្នាំ២០២០ បញ្ជាក់ពីភាពជាតំណាងបំផុត របស់សហជីពប្រជាធិបតេយ្យកម្មករ នៃរោងចក្រ ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

៩- អនុសញ្ញារួម រវាងសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជាមួយនិងក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី បានចុះបញ្ជីការលេខ ០១៣ កប/អក/វក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ដោយប្រធាននាយកដ្ឋានវិវាទការងារ។

១០- កំណត់ហេតុចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ស្ដីពីការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ។

១១- របាយការណ៍ចុះថ្ងៃ២៦ ខែកុម្ភៈ ឆ្នាំ២០២១របស់មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្ដីពីបញ្ហាក្រុមហ៊ុន ជៀន ស៊ីង និងការទូទាត់តម្លៃសេវាភ្នាក់ងារ។

១២- កំណត់ហេតុចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ស្ដីពីការសាកសួរព័ត៌មានតំណាងកម្មករនិយោជិតនៅក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ។

១៣- លិខិតចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជូនប្រធានសហជីពប្រជាធិបតេយ្យកម្មករ ស្ដីពីជូនដំណឹងស្ដីពីការមិនអាចកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតបង់ថ្លៃសេវាភ្នាក់ងារ នៃអនុសញ្ញារួម។

១៤- លិខិតលេខ ០៣៦/២១ សបក/វិវាទ ចុះថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីជូនសារណាករណីវិវាទសំណុំរឿងលេខ ០១១/២១ ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

១៥- បង្កាន់ដៃបើកប្រាក់ របស់ឈ្មោះ ពៅ សារី, ចាន់ សុភា, ផល រី និង សិត សឿន។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

១- របាយការណ៍លេខ ៤២៤ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ស្ដីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

២- កំណត់ហេតុ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ នៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

៣- វិញ្ញាបនបត្រលេខ ០១៧/២០ ក.ប/វ.ប.វ.ក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ បញ្ជាក់ពីភាពជាតំណាងបំផុត របស់សហជីពប្រជាធិបតេយ្យកម្មករ នៃរោងចក្រ ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញលេខ ១១២ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ៧រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ អញ្ជើញភាគីនិយោជកចូលរួមសវនាការ។

២- លិខិតអញ្ជើញលេខ ១១៣ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ៧រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ អញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូលិមិធីត គឺជាក្រុមហ៊ុនដែលមានសកម្មភាពការដេរសម្លៀកបំពាក់ និងមានជួលកម្មករនិយោជិតសរុបចំនួន ១០៩៧នាក់។ *(យោងតាមរបាយការណ៍លេខ ៤២៤ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូលិមិធីត)*
- សហជីពប្រជាធិបតេយ្យកម្មករនៃរោងចក្រ ជៀង ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ទទួលបានវិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត លេខ ០១៧/២០ ក.ប/វ.ប.វ.ក ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០២០។
- អនុសញ្ញារួមរវាងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ុន ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជាមួយនិងក្រុមហ៊ុន ជៀន ស៊ុន ហ្គាមេន (ខេមបូឌា) ខូអិលធីឌីនចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២០៖

  ប្រការ ១៣ ៖

  *"ក- ...*

  *ខ- កម្មករនិយោជិតដែលមិនបានចូលជាសមាជិកសហជីពប្រជាធិតេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ហើយស្ថិតក្រោមអនុសញ្ញានេះ ត្រូវបង់ថ្លៃសេវាភ្នាក់ងារនៃអនុសញ្ញារួម ចំនួន៥០% នៃអត្ថប្រយោជន៍ទទួលបាន។"*

**ចំណុចវិវាទទី ១ និងទី២៖ ភាគីសហជីពដែលមានភាពតំណាងបំផុតទាមទារឱ្យនិយោជកអនុវត្តខ្លឹមសារនៃអនុសញ្ញារួមទាំងមូល និងជាពិសេសត្រង់ប្រការ១៣ (ខ) នៃអនុសញ្ញារួម ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ និងទាមទារឱ្យនិយោជកសងប្រាក់បង់តម្លៃសេវាភ្នាក់ងារអនុសញ្ញារួម ចាប់តាំងពីថ្ងៃអនុវត្តអនុសញ្ញារួមថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០២០ រហូតដល់ការដោះស្រាយវិវាទនេះចប់សព្វគ្រប់ ការទាមទារនេះ ចំពោះតែចំនួនកម្មករនិយោជិតដែលមិនបានចូលជាសមាជិកសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូលិមិធីត**

- ភាគីសហជីពដែលមានភាពតំណាងបំផុតបញ្ជាក់ការទាមទារឱ្យនិយោជកកាត់ប្រាក់ឈ្នួលកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមចំនួន ៥០ភាគរយ នៃអត្ថប្រយោជន៍ ដែលកម្មករនិយោជិត

THE ARBITRATION COUNCIL

ទទួលបានពីអនុសញ្ញារួម នៅរៀងរាល់ពេលកម្មករនិយោជិតទទួលបានអត្ថប្រយោជន៍ពីនិយោជក តាមខ្លឹមសារចំណុច ខ ប្រការ ១៣ នៃអនុសញ្ញារួម ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ និងសងប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ដែលនិយោជកមិនបានបង់ឱ្យសហជីព ចាប់ពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ រហូតដល់ការដោះស្រាយវិវាទនេះចប់សព្វគ្រប់។

- ភាគីទាំងពីរទទួលស្គាល់ថា៖
    - ○ អនុសញ្ញារួមបានបញ្ចប់ការចរចា នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ និងបន្ទាប់ពីបានកែតម្រូវខ្លឹមសារនៃចំណុច ខ ប្រការ ១៣ តាមការណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរួច នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ អនុសញ្ញារួមត្រូវបានទទួលការចុះទិដ្ឋាការទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
    - ○ យោងតាមខ្លឹមសារចំណុច ខ ប្រការ ១៣ នៃអនុសញ្ញារួម តម្រូវឱ្យនិយោជកកាត់ប្រាក់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម ពីកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពនៃភាគីអនុសញ្ញារួមចំនួន ៥០ភាគរយ សម្រាប់បង់ថ្លៃសេវាភ្នាក់ងារអនុសញ្ញារួម ដល់សហជីពដែលជាភាគីនៃអនុសញ្ញារួម។
    - ○ បន្ទាប់ពីអនុសញ្ញារួមទទួលបានទិដ្ឋាការទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ និយោជកបានកាត់ប្រាក់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួមបង់ថ្លៃសេវាភ្នាក់ងារអនុសញ្ញារួមចំនួន ៥០ភាគរយ ស្មើនឹងចំនួន ១.៥០ដុល្លារអាមេរិក បង់ប្រាក់សេវាភ្នាក់ងារនេះតែម្តងគត់ ដោយនិយោជកកាត់ពីប្រាក់អត្ថប្រយោជន៍ រង្វាន់ធ្វើការទៀងទាត់ចំនួន ៥០ភាគរយ ដែលកម្មករនិយោជិតទទួលពីអនុសញ្ញារួមបន្ថែមចំនួន ២ដុល្លារអាមេរិក និងកាត់ពីប្រាក់អត្ថប្រយោជន៍សោហ៊ុយធ្វើដំណើរចំនួន ៥០ ភាគរយ ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួមបន្ថែមចំនួន ១ដុល្លារអាមេរិក។
    - ○ ក្រៅពីប្រាក់អត្ថប្រយោជន៍រង្វាន់ធ្វើការទៀងទាត់ និងសោហ៊ុយធ្វើដំណើរខាងលើ កម្មករនិយោជិត មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ផ្សេងទៀត ដូចខាងក្រោម៖
        - ▪ ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ១០០០រៀល បន្ថែមពីការផ្តល់ជូនរបស់និយោជកមុនមានអនុសញ្ញារួម ចំនួន ២០០០រៀល (សរុប ៣០០០រៀល),
        - ▪ ប្រាក់ធ្វើការបន្ថែមម៉ោងពេលយប់ (២ម៉ោង ពីម៉ោង ៣:០០ ដល់ម៉ោង ៥:០០) ចំនួនពី ២០០ភាគរយ (មិនទាន់បានអនុវត្តនៅឡើយ)
        - ▪ ប្រាក់ធ្វើការបន្ថែមម៉ោងនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលចំនួន ១០០ភាគរយ បន្ថែមពីលើការផ្តល់ជូនរបស់និយោជកមុនមានអនុសញ្ញារួមចំនួន ២០០ភាគរយ (សរុប ៣០០ភាគរយ)
        - ▪ ប្រាក់ថ្លៃម្សៅទឹកដោះគោចំនួន ២ដុល្លារអាមេរិក បន្ថែមពីលើការផ្តល់ជូនរបស់និយោជកមុនមានអនុសញ្ញារួមចំនួន ១០ដុល្លារអាមេរិក (សរុប ១២ដុល្លារអាមេរិកក្នុងមួយខែ)។
    - ○ និយោជកបានជូនដំណឹងទៅសហជីពដែលជាភាគីនៃអនុសញ្ញារួម បញ្ជាក់ការមិនយល់ព្រមរបស់កម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពនៃអនុសញ្ញារួម ឱ្យនិយោជកកាត់

ប្រាក់អត្ថប្រយោជន៍ធ្វើការបន្ថែមម៉ោងថ្ងៃឈប់បុណ្យបង់ថ្លៃសេវាភ្នាក់ងារអនុសញ្ញារួមម្តងទៀតនោះទេ ពីព្រោះកម្មករនិយោជិតបានបង់ម្តងរួចហើយ។

   - ចំពោះកម្មករនិយោជិតដែលជាសមាជិករបស់សហជីពដែលមានភាពជាតំណាងបំផុតត្រូវបានបង់ប្រាក់ភាគទានសហជីពចំនួន ១ដុល្លារអាមេរិក ជារៀងរាល់ខែ។

- ភាគីសហជីពដែលមានភាពតំណាងបំផុតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
   - ចំណុច ខ ប្រការ ១៣ នៃអនុសញ្ញារួម ស្តីពី អវសានប្បញ្ញត្តិ បានចែងថា កម្មករនិយោជិតដែលមិនបានចូលជាសមាជិកសហជីពប្រជាធិតេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ហើយស្ថិតក្រោមអនុសញ្ញារួមនេះ ត្រូវបង់ថ្លៃសេវាភ្នាក់ងារនៃអនុសញ្ញារួមចំនួន ៥០ភាគរយនៃអត្ថប្រយោជន៍ទទួលបាន។ ផ្នែកនេះមានន័យថា កម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពដែលមានភាពជាតំណាងបំផុតនៅពេលទទួលបានអត្ថប្រយោជន៍ម្តងៗ ដែលកើតចេញពីអនុសញ្ញារួម គឺត្រូវបង់ថ្លៃសេវាភ្នាក់ងារអនុសញ្ញារួមចំនួន ៥០ភាគរយ។
   - មាត្រា ២៦ នៃច្បាប់ស្តីសហជីព និងប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.ក.ប.ក ចុះថ្ងៃទី ២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពី ការកាត់ប្រាក់ភាគទាន និងប្រាក់សេវាភ្នាក់ងារដែលមានការអនុញ្ញាត បានចែងថា [...] សហជីពដែលមានភាពជាតំណាងបំផុតដែលតំណាងឱ្យកម្មករនិយោជិតទាំងអស់មានសិទ្ធិផ្តាច់មុខក្នុងការចរចាដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួមនូវការកំណត់តម្លៃសេវាភ្នាក់ងារសមរម្យឯកភាពមួយដែលមិនលើសពីប្រាក់វិភាគទាន និងតម្លៃផ្សេងទៀត។ តម្លៃសេវាភ្នាក់ងារនេះត្រូវបង់តែម្តងគត់។ ត្រង់មាត្រានេះ មិនបានបញ្ជាក់អំពីតម្លៃសេវាភ្នាក់ងារនេះក្នុងរយៈពេលសុពលភាពនៃអនុសញ្ញារួម និងមិនបានបញ្ជាក់អំពីការបង់តែម្តងគត់ក្នុងមួយខែ ឬក្នុងមួយឆ្នាំ ឬមួយអាណត្តិ នៃអនុសញ្ញារួម ព្រោះអនុសញ្ញារួមមានរយៈពេលអនុវត្ត ៣ឆ្នាំ បើបង់តែម្តងគត់ក្នុងរយៈពេល ៣ឆ្នាំ នៃអត្ថប្រយោជន៍ដែលទទួលបានកើតចេញពីអនុសញ្ញារួម យ៉ាងហោចណាស់តម្លៃសេវាភ្នាក់ងារអនុសញ្ញារួមស្មើ ៣៦ដុល្លារអាមេរិក ដោយសារប្រាក់ភាគទានសហជីពដែលសមាជិកបង់ក្នុងរយៈពេល ៣ឆ្នាំ ស្មើ ៣៦ដុល្លារអាមេរិក សម្រាប់សមាជិកម្នាក់ៗ។ តាមខ្លឹមសារនៃអនុសញ្ញារួមត្រង់ប្រការ ១៣ ចំណុច ខ ស្តីពី អវសានប្បញ្ញត្តិ ដែលបានចែងខាងលើ នៅពេលកម្មករនិយោជិតទទួលអត្ថប្រយោជន៍ម្តងៗ ត្រូវបង់ម្តងគត់នៃអត្ថប្រយោជន៍នោះ។
   - និយោជកត្រូវកាត់ប្រាក់អត្ថប្រយោជន៍ចំនួន ៥០ភាគរយ ពីកម្មករនិយោជិតរៀងរាល់ពេលនិយោជកផ្តល់ប្រាក់អត្ថប្រយោជន៍ដល់កម្មករនិយោជិតតាមអនុសញ្ញារួម មិនមែនកាត់តែប្រាក់អត្ថប្រយោជន៍ធ្វើការទៀងទាត់ និងប្រាក់សោហ៊ុយធ្វើដំណើរ និងកាត់តែម្តងបង់ថ្លៃសេវាភ្នាក់ងារអនុសញ្ញារួមរួចហើយឈប់បង់នោះទេ។ ករណីកម្មករនិយោជិតទទួលបានប្រាក់អត្ថប្រយោជន៍ពីអនុសញ្ញារួមរៀងរាល់ខែ និយោជកត្រូវកាត់ប្រាក់អត្ថប្រយោជន៍នេះចំនួន ៥០ភាគរយ រៀងរាល់ខែ ពីកម្មករនិយោជិតបង់ទៅសហជីពដែលជាភាគីនៃអនុសញ្ញារួម។ ការទាមទារនេះ គឺឱ្យនិយោជកអនុវត្តច្បាប់ ដូចមានចែងក្នុងអនុសញ្ញារួមដែលបានទទួលចុះបញ្ជីការទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនមែនជាការស្នើសុំនោះទេ។

- នៅពេលចុះទិដ្ឋាការអនុសញ្ញារួម ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានសួរទៅសហជីពអំពីចំណុច ខ ប្រការ ៣ នៃអនុសញ្ញារួមថា ហេតុអ្វីកំណត់ថាកាត់ប្រាក់អត្ថប្រយោជន៍របស់កម្មករនិយោជិតជារៀងរាល់ខែ ដើម្បីបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមព្រោះ កម្មករនិយោជិតមិនអាចទទួលបានប្រាក់អត្ថប្រយោជន៍រៀងរាល់ខែនោះទេ ករណីដូចជាប្រាក់ម្សៅទឹកដោះគោដែលកម្មករនិយោជិតមិនអាចទទួលបានរៀងរាល់ខែនោះទេ។ ហេតុដូចនេះហើយ សហជីពបានកែសម្រួលចំណុច ខ នេះ ដោយលុបពាក្យរៀងរាល់ខែចេញ តែខ្លឹមសារនៅដដែល មានន័យថា កាត់ប្រាក់អត្ថប្រយោជន៍ ៥០ភាគរយ ពីកម្មករនិយោជិត គឺរៀងរាល់ខែនៅពេលទទួលបានប្រាក់អត្ថប្រយោជន៍ពីអនុសញ្ញារួម ដើម្បីបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម។
- សម្រាប់កម្មករនិយោជិតដែលជាសមាជិកសហជីពដែលជាភាគីនៃអនុសញ្ញារួមត្រូវបង់ប្រាក់ភាគទានសហជីពចំនួន ១ដុល្លារអាមេរិក រៀងរាល់ខែ តែកម្មករនិយោជិតដែលមិនមែនជាសមាជិកសជីពដែលទទួលបានអត្ថប្រយោជន៍ពីអនុសញ្ញារួម បង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមតែម្ដង គឺមិនមានភាពសមធម៌សម្រាប់សហជីពដែលខិតខំចរចាអនុសញ្ញារួមនោះទេ។
- និយោជកត្រូវទទួលខុសត្រូវ ព្រោះនិយោជកបានពន្យល់ប្រាប់កម្មករនិយោជិតថា តាមច្បាប់ការបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមតែម្ដងគត់ ទើបកម្មករនិយោជិតដែលមិនមែនសមាជិកសហជីពដែលជាភាគីនៃអនុសញ្ញារួម មិនយល់ព្រមឱ្យនិយោជកកាត់ប្រាក់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួមបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមនេះ។
- និយោជកត្រូវកាត់ប្រាក់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលពីអនុសញ្ញារួម បង់ថ្លៃសេវាភ្នាក់ងារអនុសញ្ញារួមចាប់ពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ បន្ទាប់ពីអនុសញ្ញារួមបានបញ្ចប់ការចរចា មិនមែនកាត់ប្រាក់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលពីអនុសញ្ញារួមតែក្នុងខែកក្កដា ឆ្នាំ២០២០ នោះទេ។ និយោជកបានយកមូលហេតុថា ត្រូវការពេលវេលារៀបចំប្រព័ន្ធគណនេយ្យរយៈពេលពីរខែ ដូចនេះ និយោជកត្រូវសងប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមដែលនិយោជកមិនកាត់ពីកម្មករនិយោជិត ចាប់ពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ រហូតដល់ខែកក្កដា ឆ្នាំ២០២០ និងក្រោយការដោះស្រាយចប់សព្វគ្រប់។

- ភាគីនិយោជកបញ្ជាក់ពីមូលហេតុដែលមិនអាចផ្ដល់ជូនតាមការទាមទារថា ៖
  - យោងតាមខ្លឹមសារ ចំណុច ខ ប្រការ ១៣ នៃអនុសញ្ញារួម បានចែងច្បាស់ហើយថា កម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពនៃភាគីអនុសញ្ញារួម និងទទួលបានប្រាក់អត្ថប្រយោជន៍ពីអនុសញ្ញារួម ត្រូវកាត់ប្រាក់អត្ថប្រយោជន៍នេះចំនួន ៥០ភាគរយ ដើម្បីបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម និងយោងតាមតាម្រា ២៦ នៃច្បាប់ស្ដីពីសហជីព បានអនុញ្ញាតឱ្យសហជីពដែលមានភាពតំណាងបំផុតមានសិទ្ធិកំណត់អំពីប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមដាក់បញ្ចូលក្នុងអនុសញ្ញារួម នូវតម្លៃសេវាភ្នាក់ងារសមរម្យមួយដែលមិនលើសពីប្រាក់ភាគទាន និងតម្លៃផ្សេងៗ តែប្រាក់សេវានេះ កម្មករនិយោជិតត្រូវបង់តែម្ដងគត់។ និយោជកយល់ថា តាមរយៈមាត្រា ២៦ នៃច្បាប់ស្ដីពីសហជីពនេះ ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមមិនអាចលើសពីប្រាក់ភាគទានសហជីព និងប្រាក់អត្ថប្រយោជន៍ផ្សេងទៀតទេ ដោយមាត្រានេះប្រើពាក្យ និង មានន័យថាទាំងពីរ។

- កម្មករនិយោជិតយល់ច្បាស់ណាស់អំពីច្បាប់នេះ ថា ប្រាក់សេវាក្នាក់ងារអនុសញ្ញារួម គឺបង់តែម្តងគត់ មិនមែនបង់រៀងរាល់ខែ នៅពេលដែលកម្មករនិយោជិតទទួលបានប្រាក់អត្ថប្រយោជន៍ពីអនុសញ្ញារួមនោះទេ។
- ករណីច្បាប់តម្រូវឱ្យនិយោជកកាត់ប្រាក់ពីកម្មករនិយោជិតបង់ថ្លៃសេវាភ្នាក់ងារនេះរៀងរាល់ខែ និយោជកនឹងកាត់តាមច្បាប់ ពីព្រោះ ប្រាក់សេវាភ្នាក់ងារនេះ ជាប្រាក់របស់កម្មករនិយោជិត និយោជកគ្រាន់តែជាអ្នកជួយសម្រួលការងារនេះតែប៉ុណ្ណោះ។
- កម្មករនិយោជិតបានបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមនៅខែកក្កដា ឆ្នាំ២០២០ ដែលមានចំនួន ៥០ភាគរយ នៃប្រាក់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានក្នុងខែនោះរួចហើយ ហេតុនេះ កម្មករនិយោជិតមិនត្រូវបង់ទៀតទេ។
- និយោជកបានជូនដំណឹងទៅកម្មករនិយោជិតថា ត្រូវកាត់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមនៅពេលធ្វើការបន្ថែមម៉ោងថ្ងៃបុណ្យ តាមសំណើរសហជីពដែលជាភាគីនៃអនុសញ្ញារួមតែកម្មករនិយោជិតមិនយល់ព្រមឱ្យនិយោជកកាត់ប្រាក់អត្ថប្រយោជន៍ធ្វើការបន្ថែមម៉ោង ដើម្បីបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមទេ ដោយបានដាក់ជាលិខិតមកនិយោជកមិនឱ្យកាត់ប្រាក់អត្ថប្រយោជន៍ធ្វើការបន្ថែមម៉ោង ដើម្បីបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ហើយសហជីពដែលជាភាគីនៃអនុសញ្ញារួម ក៏បានទទួលលិខិតនេះដែរ និងបានចុះហត្ថលេខាទទួលស្គាល់ថាបានទទួលដែរ។
- ចំពោះលិខិតដែលនិយោជកជូនដំណឹងដល់សហជីពដែលជាភាគីនៃអនុសញ្ញារួម គឺដោយសារមានលិខិតពីកម្មករនិយោជិតដោយមានស្នាមមេដៃរបស់កម្មករនិយោជិត បដិសេធមិនឱ្យនិយោជកាត់ប្រាក់បង់ថ្លៃសេវាភ្នាក់ងារអនុសញ្ញារួមទៀត និងតាមការស្នើសុំរបស់សហជីពនៃភាគីអនុសញ្ញារួម ទើបនិយោជកចេញជាលិខិតជូនដំណឹងនេះ។
- ការអនុវត្តកាត់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមនេះ គឺចាប់អនុវត្តពីពេលដែលបានទទួលការចុះទិដ្ឋាការទទួលស្គាល់អនុសញ្ញារួមដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅខែកក្កដា ឆ្នាំ២០២០ មិនមែនពីពេលដែលបញ្ចប់ការចរចាអនុសញ្ញារួមនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ នោះទេ។

## ហេតុផលនៃសេចក្តីសម្រេច ÷

**ចំណុចវិវាទទី ១ និងទី២៖** ភាគីសហជីពដែលមានភាពតំណាងបំផុតទាមទារឱ្យនិយោជកកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមចំនួន ៥០ភាគរយ នៃអត្ថ-ប្រយោជន៍ ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម នៅរៀងរាល់ពេលកម្មករនិយោជិតទទួលបានពីនិយោជក តាមខ្លឹមសារចំណុច ខ ប្រការ១៣ នៃអនុសញ្ញារួមចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ និងសងប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមដែលនិយោជកមិនបានបង់ឱ្យសហជីព ចាប់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ រហូតដល់ការដោះស្រាយវិវាទនេះចប់សព្វគ្រប់

THE ARBITRATION COUNCIL

ភាគីសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ុន ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ដែលជាភាគីនៃអនុសញ្ញារួម បានលើកឡើងថា ខ្លឹមសារចំណុច ខ ប្រការ១៣ នៃអនុសញ្ញារួមមានន័យថា កម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពនៅពេលទទួលបានអត្ថប្រយោជន៍ម្តងៗ ពីអនុសញ្ញារួម គឺត្រូវបង់ថ្លៃសេវាភ្នាក់ងារអនុសញ្ញារួមចំនួន ៥០ភាគរយ នៅរៀងរាល់ពេលកម្មករនិយោជិតទទួលបានអត្ថប្រយោជន៍នោះពីនិយោជក ពីព្រោះកថាខណ្ឌទី២ មាត្រា២៦ នៃច្បាប់សហជីពមិនបានបញ្ជាក់អំពីការបង់តែម្តងគត់នេះ មានន័យថា តែម្តងក្នុងមួយខែ ឬក្នុងមួយឆ្នាំ ឬមួយអណត្តិនៃអនុសញ្ញារួមនោះទេ ហើយអនុសញ្ញារួមនេះគឺមានរយៈពេលអនុវត្តចំនួន ៣ឆ្នាំ។ ភាគីសហជីពបានលើកឡើងបន្ថែមទៀតថា អនុសញ្ញារួមត្រូវបានបញ្ចប់ការចរចា និងបានចុះកាលបរិច្ឆេទនៃកិច្ចព្រមព្រៀងអនុសញ្ញារួម តាំងពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ តែនិយោជកចាប់ផ្តើមអនុវត្តកាត់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមនៅខែកក្កដា ឆ្នាំ២០២០។ ដូចនេះ និយោជកត្រូវសងប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមដែលមិនទាន់បានកាត់នោះជូនសហជីព។

យ៉ាងណាមិញ ភាគីនិយោជកបានលើកឡើងថា ខ្លឹមសារចំណុច ខ ប្រការ១៣ នៃអនុសញ្ញារួមមានន័យថា កម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពនៃភាគីអនុសញ្ញារួម ដែលទទួលបានប្រាក់អត្ថប្រយោជន៍ពីអនុសញ្ញារួម ត្រូវកាត់ប្រាក់អត្ថប្រយោជន៍នេះចំនួន ៥០ភាគរយ ដើម្បីបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ហើយកម្មករនិយោជិតត្រូវបង់តែម្តងគត់ យោងតាមកថាខណ្ឌទី២ មាត្រា២៦ នៃច្បាប់សហជីព។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតដើម្បីបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមតែម្តងគត់ត្រឹមត្រូវតាមច្បាប់ដែរ ឬទេ ?

កថាខណ្ឌទី២ មាត្រា ២៦ នៃច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ ចែងថា៖ *"សហជីពមានភាពជាតំណាងបំផុតដែលតំណាងឱ្យកម្មករនិយោជិតទាំងអស់ មានសិទ្ធិផ្តាច់មុខក្នុងការចរចា ដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួម នូវការកំណត់តម្លៃសេវាភ្នាក់ងារសមមូលឯកភាពមួយដែលមិនលើសប្រាក់ភាគទាន និងតម្លៃផ្សេងទៀត។ តម្លៃសេវាភ្នាក់ងារនេះ ត្រូវបានបង់តែម្តងគត់។"*

កថាខណ្ឌទី១ ប្រការ ៧ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ ចែងថា៖ *"សហជីពមានភាពជាតំណាងបំផុត មានសិទ្ធិផ្តាច់មុខក្នុងការចរចាដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួម នូវការកំណត់តម្លៃសេវាភ្នាក់ងារសមមូលឯកភាពមួយ ដែលមិនលើសប្រាក់ភាគទានប្រចាំខែរបស់សមាជិកខ្លួន។ តម្លៃសេវាភ្នាក់ងារនេះ ត្រូវបានបង់តែម្តងគត់។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ០៥៩/២០-ខេមបូឌា អ៊ែរផត មែនីជ្ជមែន សឺវីស (CAMS) ហេតុផលនៃចំណុចវិវាទទី២ បានបកស្រាយកថាខណ្ឌទី២ មាត្រា ២៦ នៃច្បាប់ស្តីពីសហជីព និងកថាខណ្ឌទី១ ប្រការ ៧ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ខាងលើថា ៖ *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែសហជីពមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិចរចាជាមួយនិយោជក ក្នុងការដាក់បញ្ចូលតម្លៃសេវាភ្នាក់ងារទៅក្នុងអនុសញ្ញារួម ហើយតម្លៃសេវាភ្នាក់ងារនេះមិនអាចលើសពីប្រាក់ភាគទានប្រចាំខែរបស់សមាជិកសហជីពបានឡើយ និងត្រូវបង់តែម្តងគត់។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ មានន័យថា តម្លៃសេវាភ្នាក់ងារអនុសញ្ញារួមនេះ គឺមិនអាចលើសពីប្រាក់

ភាគទានប្រចាំខែរបស់សមាជិកខ្លួនត្រូវបង់ឡើយ ហើយការបង់ប្រាក់សេវាភ្នាក់ងារនេះ គឺត្រូវបង់តែម្តងគត់នៅពេលអនុសញ្ញារួមចាប់ផ្តើមអនុវត្ត។

យោងតាមចំណុច ខ ប្រការ ១៣ នៃអនុសញ្ញារួមរវាងសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ិន ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជាមួយនិងក្រុមហ៊ុន ជៀន ស៊ិន ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ បានកំណត់ថា៖ *"កម្មករនិយោជិតដែលមិនបានចូលជាសមាជិកសហជីពប្រជាធិប-តេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ហើយស្ថិតក្រោមអនុសញ្ញានេះ ត្រូវបង់ថ្លៃសេវាភ្នាក់ងារនៃអនុសញ្ញារួម ចំនួន៥០% នៃអត្ថប្រយោជន៍ទទួលបាន។"*

ផ្អែកតាមចំណុច ខ ប្រការ ១៣ នៃអនុសញ្ញារួមខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពប្រជាធិបតេយ្យកម្មករ ដែលស្ថិតនៅក្រោមអនុញ្ញារួម ដើម្បីបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ដូចដែលបានកំណត់នៅក្នុងអនុ-សញ្ញារួម ដោយការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារនេះ គឺតែម្តងគត់នៅពេលអនុសញ្ញារួមចាប់ផ្តើមអនុវត្ត ដោយយោងតាមខណ្ឌទី២ មាត្រា ២៦ និងកថាខណ្ឌទី១ ប្រការ ៧ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ខាងលើ។

យោងតាមអង្គហេតុ ភាគីទាំងពីរទទួលស្គាល់ថា និយោជកបានកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពនៃភាគីអនុសញ្ញារួម ដើម្បីបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម នៅខែកក្កដា ឆ្នាំ២០២០ ចំនួន ១.៥០ដុល្លារអាមេរិក ដែលស្មើនឹងចំនួន ៥០ភាគរយ នៃប្រាក់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានបន្ថែមពីលើប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់សោហ៊ុយធ្វើដំណើរ ម្តងរួចហើយ បន្ទាប់ពីអនុសញ្ញារួមនេះបានចុះទិដ្ឋាការ នៅខែកក្កដា ឆ្នាំ២០២០។

យោងតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកបានអនុវត្តកាតព្វកិច្ចកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមម្តងរួចហើយ ដែលមានចំនួន ៥០ភាគរយនៃប្រាក់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានទៅឱ្យសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ជៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី តាមចំណុច ខ ប្រការ១៣ នៃអនុសញ្ញារួម។ ជាងនេះទៀត យោងតាមច្បាប់ និងការបកស្រាយខាងលើ ការកាត់ប្រាក់សេវាភ្នាក់ងារនេះ គឺត្រូវធ្វើឡើងតែម្តងគត់ នៅពេលដែលអនុ-សញ្ញារួមចាប់ផ្តើមអនុវត្ត។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់រកឃើញថា ការអនុវត្តរបស់និយោជក ដែលកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ថ្លៃសេវាភ្នាក់ងារអនុសញ្ញារួមតែម្តងគត់នេះ គឺធ្វើឡើងត្រឹមត្រូវតាមកថាខណ្ឌទី២ មាត្រា ២៦ នៃច្បាប់ស្តីពីសហជីព និងកថាខណ្ឌទី១ ប្រការ ៧ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីសហជីពដែលមានភាពតំណាងផុត ឱ្យនិយោជកកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមចំនួន ៥០ភាគរយ នៃអត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម នៅរៀងរាល់ពេលកម្មករនិយោជិតទទួលបានពីនិយោជកតាមខ្លឹមសារចំណុច ខ ប្រការ១៣ នៃអនុសញ្ញារួម ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ និងសងប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមដែលនិយោជកមិនបានបង់ឱ្យសហជីព ចាប់ពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ រហូតដល់ការដោះស្រាយវិវាទនេះចប់សព្វគ្រប់។

ARBITRATION COUNCIL

យោងតាមការបង្ហាញកស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី ១និងទី២ ៖**

- បដិសេធការទាមទាររបស់ភាគីសហជីពដែលមានភាពតំណាងផុត ឱ្យនិយោជកកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមចំនួន ៥០ភាគរយ នៃអត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម នៅរៀងរាល់ពេលកម្មករនិយោជិតទទួលបានពីនិយោជក តាមខ្លឹមសារចំណុច ខ ប្រការ១៣ នៃអនុសញ្ញារួម ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ និងសងប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ដែលនិយោជកមិនបានបង់ឱ្យសហជីព ចាប់ពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ រហូតដល់ការដោះស្រាយវិវាទនេះចប់សព្វគ្រប់។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់ជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង យោងតាម អនុសញ្ញារួម រវាងសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជាមួយនិងក្រុមហ៊ុន ជៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ចុះបញ្ជីលេខ០១៣ កប/អក/វក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា ៖ ---------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ីន គីមស៊ាន**

ហត្ថលេខា ៖---------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ---------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

ឧបសម្ព័ន្ធនៃសេចក្ដីបង្គាប់លេខ ០១១/២១-ធៀន ស៊ុង ហ្គាមេន

## យោបល់ជំទាស់ទៅលើសេចក្ដីសម្រេច
## នៃសំណុំរឿងលេខ ០១១/២១-ធៀន ស៊ុង ហ្គាមេន

## ដោយអាជ្ញាកណ្ដាល ស៊ីន គីមស៊ាន
## ដែលជ្រើសរើសដោយភាគីសហជីពកម្មករនិយោជិត

ប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ បានចែងថា៖

*"ក្រុមអាជ្ញាកណ្ដាលត្រូវកត់ត្រាលស់សេចក្ដីម្រេចរបស់ខ្លួនក្នុងសេចក្ដីបង្គាប់មួយ ដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្ដាលទាំង ០៣ រូប។ ក្នុងករណីដែលអាជ្ញាកណ្ដាលណាម្នាក់ មិនឯកភាពនឹងសេចក្ដីសម្រេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយក្នុងសេចក្ដីបង្គាប់នោះ "*។

យោងតាមប្រការនេះ ខ្ញុំអាជ្ញាកណ្ដាល ស៊ីន គីមស៊ាន សូមផ្ដល់នូវយោបល់ជំទាស់ទៅនឹងហេតុផល នៃសេចក្ដីសម្រេចក្នុងសេចក្ដីបង្គាប់លេខ ០១១/២១-ធៀន ស៊ុង ហ្គាមេន ដែលបដិសេធការទាមទារ របស់ភាគីសហជីព។

## ហេតុផលនៃយោបល់ជំទាស់÷

១. ហេតុផលនៃយោបល់ជំទាស់លើសេចក្ដីបង្គាប់នេះមាន២ (ពីរ) គឺ៖

<u>ចំណុចទី១</u> - ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនបានពន្យល់ពីការហេតុផលនៃការបដិសេធមិនពិចារណារបស់ខ្លួនឱ្យបានច្បាស់លាស់ទៅនឹងការទាមទាររបស់ភាគីសហជីព ហើយដែលការទាមទារនោះ ភាគីសហជីពបានបញ្ជាក់បន្ថែមនៅក្នុងសវនាការ និង

<u>ចំណុចទី២</u> - ការយល់ឃើញរបស់ខ្ញុំលើការទាមទាររបស់ភាគីសហជីពលើការកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ចំនួន ៥០ភាគរយ នៃអត្ថប្រយោជន៍ ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម។

## ចំណុចទី១

២. ភាគីសហជីពបានបញ្ជាក់ពីការទាមទាររបស់ខ្លួនឱ្យនិយោជកកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ដែលមានក្រៅពីប្រាក់អត្ថប្រយោជន៍ង្វាន់ធ្វើការទៀងទាត់ និងសោហ៊ុយធ្វើដំណើរខាងលើ កម្មករនិយោជិតមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ផ្សេងទៀត ដូចខាងក្រោម៖

- ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ១០០០រៀល បន្ថែមពីការផ្ដល់ជូនរបស់និយោជកមុនមានអនុសញ្ញារួម ចំនួន ២០០០រៀល (សរុប ៣០០០រៀល),
- ប្រាក់ធ្វើការបន្ថែមម៉ោងពេលយប់ (២ម៉ោង ពីម៉ោង ៣:០០ ដល់ម៉ោង ៥:០០) ចំនួនពី ២០០ ភាគរយ

THE ARBITRATION COUNCIL

- ប្រាក់ធ្វើការបន្ថែមម៉ោងនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលចំនួន ១០០ភាគរយ បន្ថែមពីលើការផ្តល់ជូនរបស់និយោជកមុនមានអនុសញ្ញារួមចំនួន ២០០ភាគរយ (សរុប ៣០០ភាគរយ)
- ប្រាក់ថ្លៃម្ស៉ៅទឹកដោះគោចំនួន ២ដុល្លារអាមេរិក បន្ថែមពីលើការផ្តល់ជូនរបស់និយោជកមុនមានអនុសញ្ញារួមចំនួន ១០ដុល្លារអាមេរិក (សរុប ១២ដុល្លារអាមេរិក ក្នុងមួយខែ)។

៣. ចំណុចនេះមាននៅក្នុងអង្គហេតុនៃសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល (ទំព័រ៩) និងនៅក្នុងសវនាការ ភាគីសហជីពបានបញ្ជាក់បន្ថែម ក្រោយពីមានការសួរបញ្ជាក់ពីក្រុមអាជ្ញាកណ្តាល ខ្ញុំយល់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលគួរធ្វើការបញ្ជាក់ពីហេតុផលនៃការបដិសេធលើការទាមទារគ្រប់ចំណុចដែលភាគីសហជីពបានទាមទារ និងលើកឡើង ដើម្បីឱ្យភាគីទាមទារបានយល់ពីការបដិសេធនោះ។

## ចំណុចទី២

៤. ចំពោះការទាមទាររបស់ភាគីសហជីពលើការកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ចំនួន ៥០ភាគរយ នៃអត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម ដែលជាប្រាក់អត្ថប្រយោជន៍នៅមិនទាន់បានអនុវត្តនៅឡើយ មាន (១) ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ១០០០រៀល បន្ថែមពីការផ្តល់ជូនរបស់និយោជកមុនមានអនុសញ្ញារួម ចំនួន ២០០០រៀល (សរុប ៣០០០រៀល), (២) ប្រាក់ធ្វើការបន្ថែមម៉ោងពេលយប់ (២ម៉ោង ពីម៉ោង ៣:០០ ដល់ម៉ោង ៥:០០) ចំនួនពី ២០០ភាគរយ, (៣) ប្រាក់ធ្វើការបន្ថែមម៉ោងនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលចំនួន ១០០ភាគរយ បន្ថែមពីលើការផ្តល់ជូនរបស់និយោជកមុនមានអនុសញ្ញារួមចំនួន ២០០ភាគរយ (សរុប ៣០០ភាគរយ), និង(៤) ២ ដុល្លារអាមេរិក បន្ថែមពីលើការផ្តល់ជូនរបស់និយោជកមុនមានអនុសញ្ញារួមចំនួន ១០ដុល្លារអាមេរិក (សរុប ១២ ដុល្លារអាមេរិក ក្នុងមួយខែ)។

៥. យោងតាមប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ប្រការ ៧ កថាខណ្ឌទី១ ចែងថា៖

> *"សហជីពមានភាពជាតំណាងបំផុត មានសិទ្ធិផ្តាច់មុខក្នុងការចរចាដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួមនូវការកំណត់តម្លៃសេវាភ្នាក់ងារសមម្យឯកភាពមួយ ដែលមិនលើសប្រាក់ភាគទានប្រចាំខែរបស់សមាជិកខ្លួន។ តម្លៃសេវាភ្នាក់ងារនេះត្រូវបានបង់តែម្តងគត់។"*

៦. ខ្ញុំយល់ថា ប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ប្រការ ៧ កថាខណ្ឌទី១កំណត់តម្លៃសេវាភ្នាក់ងារសមម្យឯកភាពមួយ ដែលមិនលើសប្រាក់ភាគទានប្រចាំខែរបស់សមាជិកខ្លួន និងតម្លៃសេវាភ្នាក់ងារនេះ ត្រូវបានបង់តែម្តងគត់។

៧. ខ្ញុំយល់ថាប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក នេះ មិនបានកំណត់ពីអត្ថប្រយោជន៍ជាក់លាក់ណាមួយ ឬអត្ថប្រយោជន៍ គឺរួមគ្នាមានតែមួយ នៅពេលណាដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម។ ដូច្នេះ ៣០០ ក.ប/ប្រ.ក.គ.ប.ក នេះ ទុកសិទ្ធិឱ្យភាគីសហជីពទាមទារការកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ចំនួន ៥០ភាគរយ នៃអត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម ដែលជាប្រាក់អត្ថប្រយោជន៍មិនទាន់បានអនុវត្ត ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម។

៨. យោងតាមច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ មាត្រា ២៦ កថាខណ្ឌទី២ ស្តីពីការកាត់ភាគទាន និងប្រាក់សេវាភ្នាក់ងារដែលមានការអនុញ្ញាត ចែងថា៖

*"សហជីពមានភាពជាតំណាងបំផុតដែលតំណាងឲ្យកម្មករនិយោជិតទាំងអស់ មានសិទ្ធិផ្តាច់មុខក្នុងការចរចា ដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួមនូវការកំណត់តម្លៃសេវាភ្នាក់ងារសមមូលឯកភាពមួយ ដែលមិនលើសប្រាក់ភាគទាន និងតម្លៃផ្សេងទៀត។ តម្លៃសេវាភ្នាក់ងារនេះត្រូវបានបង់តែម្តងគត់។"*

៩. ខ្ញុំយល់ថា ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ មាត្រា ២៦ កថាខណ្ឌទី២ នេះ កំណត់តម្លៃសេវាភ្នាក់ងារសមមូលឯកភាពមួយ ដែលមិនលើសប្រាក់ភាគទាន និងតម្លៃផ្សេងទៀត ហើយនិងតម្លៃសេវាភ្នាក់ងារនេះត្រូវបានបង់តែម្តងគត់។

១០. ខ្ញុំយល់ថា ក៏មិនបានកំណត់ពីអត្ថប្រយោជន៍ជាក់លាក់ណាមួយ ឬអត្ថប្រយោជន៍ គឺរួមគ្នាមានតែមួយ នៅពេលណាដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម។ ដូច្នេះ ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ មាត្រា ២៦ កថាខណ្ឌទី២ នេះ ក៏ទុកសិទ្ធិឱ្យភាគីសហជីពទាមទារការកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ចំនួន ៥០ភាគរយ នៃអត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម ដែលជាប្រាក់អត្ថប្រយោជន៍មិនទាន់បានអនុវត្ត ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម។

១១. ខ្ញុំក៏បានសម្គាល់ឃើញថា និយោជកបានបញ្ជាក់ពីតាមមាត្រា ២៦ នៃច្បាប់ស្តីពីសហជីពនេះ ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមមិនអាចលើសពីប្រាក់ភាគទានសហជីព និងប្រាក់អត្ថប្រយោជន៍ផ្សេងទៀតទេ ដោយមាត្រានេះ ប្រើឈ្នាប់ "និង" ថាមានន័យថាទាំងពីរ។

១២. ខ្ញុំយល់ថា ចំពោះ ឈ្នាប់ "និង" មានន័យថាទាំងពីរ ដែលលើកឡើងដោយនិយោជកនេះ ក្នុងសំណុំរឿងនេះ គឺជាសំដៅដល់ចំនួនទឹកប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ដែលមិនអាចលើសពីប្រាក់ភាគទានសហជីព និងប្រាក់អត្ថប្រយោជន៍ផ្សេងទៀត (ចំនួនទឹកប្រាក់សេវាភ្នាក់ងារអនុសញ្ញារួមមិនអាចលើសពី (≤) មានន័យមិនអាចកាត់លើសពីប្រាក់ភាគទានសហជីព និងចំនួនប្រាក់អត្ថប្រយោជន៍ផ្សេងទៀត។

១៣. ខ្ញុំយល់ថា ឈ្នាប់ "និង" មានន័យ គឺសំដៅដល់ចំនួនទឹកប្រាក់ដែលកាត់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានបង់សេវាភ្នាក់ងារអនុសញ្ញារួម ពីព្រោះឈ្នាប់ "និង" នេះភ្ជាប់នឹងប្រាក់ភាគទានសហជីព និងចំនួនប្រាក់អត្ថប្រយោជន៍ផ្សេងទៀត តែមិនមានន័យពាក់ព័ន្ធនឹងការកាត់ប្រាក់អត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបាន ដែលមិនទាន់បានអនុវត្តនោះទេ។

១៤. ខ្ញុំយល់ថា ដោយសារមិនមានច្បាប់ និងបទបញ្ញត្តិចែងឱ្យបានច្បាស់លាស់ និងជាក់លាក់ពីការកាត់អត្ថប្រយោជន៍ផ្សេងៗ បង់សេវាភ្នាក់ងារអនុសញ្ញារួម ក្រុមប្រឹក្សាអាជ្ញាកណ្តាលគួរពិចារណាទៅតាមគោលការណ៍សមធម៌ ដោយហេតុថា កម្មករនិយោជិតត្រូវមានកាតព្វកិច្ចផ្តល់ការតបស្នងទៅការងារតំណាងដោយសុចរិតក្នុងការចរចាលើលក្ខខណ្ឌការងារ អនាម័យសន្តិសុខការងារ និងអត្ថប្រយោជន៍ផ្សេងៗនេះ សម្រាប់កម្មករនិយោជិតទាំងមូលនៅក្នុងក្រុមហ៊ុន ធៀន ស៊ុន ហ្គាមេន (ខេមបូឌា) ខូអិលធិឌី។

១៥. ខ្ញុំយល់ថា សហជីពដែលទទួលបានភាពតំណាងបំផុតសហជីពមានសិទ្ធិ និងតួនាទីក្នុងការអនុវត្តការងារជាតំណាងក្នុងការចរចាដោយសុច្ចរិតក្នុងគោលបំណងឱ្យមានការព្រមព្រៀងជាសមូហភាព ដោយផ្តោតទៅលើលក្ខខណ្ឌការងារ អនាម័យសន្តិសុខការងារ និងអត្ថប្រយោជន៍ផ្សេងៗ សម្រាប់សមាជិក និងកម្មករនិយោជិតដែលមិនមែនជាសមាជិករបស់ខ្លួន។

១៦. យោងប្រការ១៣ ចំណុច ខ នៃអនុសញ្ញារួមចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ចែងថា៖

> *"ខ - កម្មករនិយោជិតដែលមិនបានចូលជាសមាជិកសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ធៀន ស៊ីង ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ជាមួយនិងក្រុមហ៊ុន ធៀន ស៊ីង ហ្គាមេន (ខេមបូឌា) ហើយស្ថិតនៅក្រោមអនុសញ្ញានេះ ត្រូវបង់ថ្លៃសេវាភ្នាក់ងារនៃអនុសញ្ញារួម ចំនួន ៥០% នៃអត្ថប្រយោជន៍ទទួលបាន។"*

១៧. ខ្ញុំយល់ថា ប្រការ១៣ ចំណុច ខ នៃអនុសញ្ញារួមចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ នេះ មិនមានពាក្យថា "នៅរៀងរាល់ពេល" នោះទេ ដូចនេះ ការលើកឡើងរបស់ភាគីសហជីពមិនត្រឹមត្រូវតាមប្រការ១៣ ចំណុច ខ នៃអនុសញ្ញារួម ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០នេះទេ។

១៨. ខ្ញុំយល់ថា កម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពនៃភាគីអនុសញ្ញារួម គួរតែបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ចំនួន ៥០ភាគរយ នៃប្រាក់អត្ថប្រយោជន៍ដែលកម្មករ និយោជិតទទួលបានបន្ថែមពីលើប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ១.០០០រៀល, ប្រាក់ធ្វើការបន្ថែមម៉ោងពេលយប់ (២ម៉ោង ពី ម៉ោង ៣:០០ ដល់ម៉ោង ៥:០០) ចំនួនពី ២០០ភាគរយ, ប្រាក់ធ្វើការបន្ថែមម៉ោងនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលចំនួន ១០០ភាគរយ, និង ២ដុល្លារអាមេរិក បន្ថែមពីលើការផ្តល់ជូនរបស់និយោជកមុនមានអនុសញ្ញារួម តែមិនលើសប្រាក់ភាគទានប្រចាំខែរបស់សមាជិក ចំនួនមួយដងគត់ បន្ទាប់ពីអនុសញ្ញារួមនេះបានចុះទិដ្ឋាការនៅខែកក្កដា ឆ្នាំ២០២០។

១៩. យោងតាមច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ មាត្រា ៦១ ស្តីពីការរក្សាឯកសារដែលជាប់ទាក់ទងនឹងការកាត់ប្រាក់ភាគទាន និងប្រាក់សេវាភ្នាក់ងារ ចែងថា៖

> *"និយោជកត្រូវរក្សាទុកកំណត់ត្រាទាំងឡាយ នៅពេលណាដែលខ្លួនបានកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីបង់ភាគទានសហជីព ឬប្រាក់សេវាភ្នាក់ងារ។ កំណត់ត្រាទាំងនេះត្រូវដាក់បញ្ចូលនូវកាលបរិច្ឆេទដែលបានកាត់នេះ ត្រូវបានអនុញ្ញាតឲ្យធ្វើឡើងដោយកម្មករនិយោជិតពាក់ព័ន្ធកាលបរិច្ឆេទ និងចំនួនប្រាក់ភាគទានបានកាត់សម្រាប់កម្មករនិយោជិតម្នាក់ៗ និងកាលបរិច្ឆេទ និងចំនួនទឹកប្រាក់ដែលផ្ទេរទៅឱ្យសហជីពពាក់ព័ន្ធ។..."*

២០. ខ្ញុំយល់ថា និយោជកមានកាតព្វកិច្ចត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីផ្ទេរទៅឱ្យសហជីពដោយអនុវត្តតាមអនុសញ្ញារួម និងនិយោជកអាចបំពេញកាតព្វកិច្ចកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត និងផ្ទេរទៅឱ្យសហជីពដើម្បីអនុវត្តតាមអនុសញ្ញារួមបាន ក្រោយពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត។

២១. ខ្ញុំយល់ថា ដោយយោងតាមច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ មាត្រា ៦១ ដែលតម្រូវឱ្យមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត ដូច្នេះ ភាគីសហជីពក្នុងសំណុំរឿងនេះត្រូវទទួលការយល់ព្រម ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត ដើម្បីទាមទារឱ្យនិយោជកកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ចំនួន ៥០ភាគរយ នៃអត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបាននៃអនុសញ្ញារួម ដែលជាប្រាក់អត្ថប្រយោជន៍នៅមិនទាន់បានអនុវត្តបង់ថ្លៃសេវាភ្នាក់ងារនៅឡើយនោះ។

ARBITRATION COUNCIL

ហេតុនេះ ខ្ញុំយល់ថា៖

១) ក្រុមប្រឹក្សាអាជ្ញាកណ្ដាលគួរតែពន្យល់ពីការហេតុផលនៃការបដិសេធមិនពិចារណាការទាមទាររបស់ហាជីពខ្លួនឱ្យបានច្បាស់លាស់ទៅនឹងការទាមទារទាំងអស់របស់ភាគីសហជីព។

២) ក្រុមប្រឹក្សាអាជ្ញាកណ្ដាលគួរពិចារណាទៅតាមគោលការណ៍សមធម៌ ដោយហេតុថា កម្មករនិយោជិតត្រូវមានកាតព្វកិច្ចផ្ដល់ការតបស្នងទៅការងារតំណាង ដោយសុច្ចរិតក្នុងការចរចាលើលក្ខខណ្ឌការងារ អនាម័យសន្តិសុខការងារ និងអត្ថប្រយោជន៍ផ្សេងៗនេះ សម្រាប់កម្មករនិយោជិតទាំងមូលនៅក្នុងក្រុមហ៊ុន ធៀន ស៊ុន ហ្គាមេន (ខេមបូឌា) ខូអិលធីឌី ដោយសារមិនមានច្បាប់ និងបទបញ្ញត្តចែងឱ្យបានច្បាស់លាស់ និងជាក់លាក់ពីការកាត់អត្ថប្រយោជន៍ផ្សេងៗបង់សេវាភ្នាក់ងារអនុសញ្ញារួម។

៣) ភាគីសហជីពក្នុងសំណុំរឿងនេះ ត្រូវទទួលការយល់ព្រម ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត ដើម្បីទាមទារឱ្យនិយោជកកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតបង់ប្រាក់សេវាភ្នាក់ងារអនុសញ្ញារួម ចំនួន ៥០ភាគរយ នៃអត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពីអនុសញ្ញារួម ដែលជាប្រាក់អត្ថប្រយោជន៍នៅមិនទាន់បានអនុវត្តបង់ថ្លៃសេវាភ្នាក់ងារនៅឡើយ និងតែមួយដងគត់។

ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១

ហត្ថលេខាអាជ្ញាកណ្ដាល

ស៊ីន គីមស៊ាន